# ចៅក្រម និង ព្រះរាជអាជ្ញា

ចៅក្រម ព្រះរាជអាជ្ញាជាន់ខ្ពស់

ចៅក្រម ព្រះរាជអាជ្ញាជាន់ទាប



# ចៅក្រម និង ព្រះរាជអាជ្ញា

ចៅក្រម និងព្រះរាជអាជ្ញាមានការទទួលខុសត្រូវការងារផ្សេងគ្នាក៏ដោយ ពាក្យថា "ចៅក្រម" ដែលគេប្រើក្នុងន័យទូទៅសំរាប់ហៅក្របខ័ណ្ឌអ្នកទាំងនោះ គឺមិនមែនសំរាប់តែចៅក្រមអង្គុយកាត់ក្តីប៉ុណ្ណោះទេ ប៉ុន្តែព្រះរាជអាជ្ញាក៏មានក្របខ័ណ្ឌជាចៅក្រមផងដែរ ។ ដូចនេះពាក្យថា "ចៅក្រម" ត្រូវបានកំណត់ជាពីរប្រភេទ គឺ÷ ចៅក្រមអាសនៈ (ចៅក្រមអង្គុយ) និង ចៅក្រមខាងអយ្យការ (ចៅក្រមឈរ ) ។

# ចៅក្រមអាសនៈ ( ចៅក្រមអង្គុយ )

ចៅក្រមនេះសួររឿងហើយជំនុំជំរះដោយចេញសាលក្រម ( Judgement ) ឬសាលដីកា ( Ordinance ) នានា ។ ក្នុងរឿងរដ្ឋប្បវេណី តាមលទ្ធផល អាចចេញជាដីកាកិច្ចការប្រញាប់ ដីកាលើកពាក្យបណ្តឹង ដីកាបំបែករឿង និងដីកាបំបែកលំនៅជាបណ្តោះអាសន្ន ។ល។

មាត្រា ១២៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា÷ ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាម ប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។ មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ច នេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

# ចៅក្រមអាសនៈ ( ចៅក្រមអង្គុយ )

( ត )...

មាត្រា ១៣០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា÷ គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលបន្ទុកអំណាចតុលាការបានឡើយ ។ ព្រះមហាក្សត្រជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

មាត្រា ១៣៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានថា÷ ចៅក្រមមិនអាចត្រូវគេដកហូតមុខទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

# ចៅក្រមអយ្យការ ( ចៅក្រមឈរ )

ចៅក្រមនេះរួមមាន÷ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង ដែលតំណាងឱ្យអំណាចនីតិប្រតិបត្តិនៅមុខសាលាជម្រះក្តី ។ អគ្គព្រះរាជអាជ្ញាដឹកនាំ មហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងព្រះរាជអាជ្ញាដឹកនាំអយ្យការអមសាលាជម្រះក្តីជាន់ទាប ។

# ◆ ចៅក្រមអយ្យការ ( ចៅក្រមឈរ )

( ត )...

ចៅក្រមអយ្យការត្រូវពិនិត្យការគ្រប់ច្បាប់  ធ្វើការចោទប្រកាន់ទោសនៅជនល្មើសពីបទព្រហ្មទណ្ឌ ឃ្លាំមើលការប្រព្រឹត្តទៅនៃនីតិវិធី ។ អាយ្យការទទួលបន្ទុកទទួលការពារផលប្រយោជន៍ទូទៅរបស់សង្គម  ។ គេហៅថា "ចៅក្រមឈរ" ពីព្រោះគាត់ធ្វើការចោទប្រកាន់ប្តឹងទៅតុលាការ ដោយក្រោកឈរនៅពេលធ្វើសាវនាការ ។ ព្រះរាជអាជ្ញាអាចទទួលបញ្ជាឱ្យធ្វើការចោទប្រកាន់ពីរដ្ឋមន្ត្រីយុត្តិធម៌បាន ។

មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា÷

មានតែអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

# ◆ ចៅក្រមអយ្យការ ( ចៅក្រមឈរ )

- ក្នុងរឿងព្រហ្មទណ្ឌ÷ អង្គអយ្យការជាម្ចាស់នៃបណ្ដឹងអាជ្ញា និងធ្វើសេចក្ដីសន្និដ្ឋានទោសដោយតាំងខ្លួនជាគូប្ដីដើមជាដំរាប ។

- ក្នុងរឿងរដ្ឋប្បវេណី និងរឿងក្ដីផ្សេងៗទៀត÷ អយ្យការជាគូក្ដីរណប គឺគ្រាន់តែជាអ្នកឱ្យយោបល់ បើយើងឃើញថាជាការគួរ ។ ប៉ុន្តែក្នុងរឿងដែលទាក់ទងដល់របៀបរៀបរយសណ្ដាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍ អនីតិជន ឬអសមត្ថជន តំណាងអយ្យការត្រូវតាំងខ្លួនជាគូក្ដីដើមដូចក្នុងរឿងព្រហ្មទណ្ឌដូច្នោះដែរ ។

## ◆ ចៅក្រមអយ្យការ ( ចៅក្រមឈរ )

ព្រះរាជអាជ្ញាមានបេសកកម្មទទួលបណ្ដឹងពីជនណាម្នាក់ ឬពីមន្ត្រីនគរបាលយុត្តិធម៌  ទទួលកំណត់ហេតុពីមន្ត្រីនគរបាលយុត្តិធម៌  ធ្វើការស៊ើបអង្កេតបឋម នឹងកេណ្ឌកម្លាំងសាធារណៈ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

# ដកស្រង់ចេញពី៖

# សៀវភៅ សេចក្ដីផ្ដើមនៃនីតិ របស់លោកគ្រូ ង៉ុយ ធឿន